(ពិន្ទុ 4) 1. $Z_1^2=8\sqrt{3}+8i$ ពិត (1pt)

ព្រោះថា

$Z_1^2=8+4\sqrt{3}-(8-4\sqrt{3})+2(6-2)i$ (2pt)

$Z_1^2=8\sqrt{3}+8i$ (1pt)

(ពិន្ទុ 4) 2. $|Z_2|=\sqrt{2}$ មិនពិត (1pt)

ព្រោះថា

$|Z_2|=\frac{|1+i|}{|\sqrt{3}+i|}=\frac{\sqrt{2}}{2}$ (3pt)

(ពិន្ទុ 4) 3. $\arg(Z_1^2)=\frac{5\pi}{6}+2k\pi$; $k\in\mathbb{Z}$ មិនពិត (1pt)

ព្រោះថា

$Z_1^2=8\sqrt{3}+8i$; $|Z_1^2|=16$ (1pt)

$\begin{cases}\cos\alpha=\frac{8\sqrt{3}}{16}=\frac{\sqrt{3}}{2}\\ \sin\alpha=\frac{8}{16}=\frac{1}{2}\end{cases}$ (1pt) $\Rightarrow \alpha=\frac{\pi}{6}+2k\pi$; $k\in\mathbb{Z}$ (1pt)

(ពិន្ទុ 4) 4. $Z_2=\frac{\sqrt{2}}{2}\left(\cos\frac{\pi}{12}+i\sin\frac{\pi}{12}\right)$ ពិត (1pt)

ព្រោះថា

$Z_2=\frac{1+i}{\sqrt{3}+i}=\frac{\sqrt{2}\left(\cos\frac{\pi}{4}+i\sin\frac{\pi}{4}\right)}{2\left(\cos\frac{\pi}{6}+i\sin\frac{\pi}{6}\right)}$ (2pt)

$Z_2=\frac{\sqrt{2}}{2}\left(\cos\frac{\pi}{12}+i\sin\frac{\pi}{12}\right)$ (1pt)

(ពិន្ទុ 5) 5. បើ $x=y$ នោះ $\arg(Z)=\frac{\pi}{4}+2k\pi$; $k\in\mathbb{Z}$ មិនពិត (1pt)

ព្រោះថា

$Z=x+ix$

$|Z|=\sqrt{2x^2}=|x|\sqrt{2}$ (1pt)

• បើ $x>0 \to |Z|=x\sqrt{2}$

$Z=x\sqrt{2}\left(\frac{\sqrt{2}}{2}+i\frac{\sqrt{2}}{2}\right)$

$=x\sqrt{2}\left(\cos\frac{\pi}{4}+i\sin\frac{\pi}{4}\right)$

$\to \arg(Z)=\frac{\pi}{4}+2k\pi$; $k\in\mathbb{Z}$ (1pt)

• បើ $x<0 \Rightarrow |Z|=-x\sqrt{2}$

$Z=-x\sqrt{2}\left(-\frac{\sqrt{2}}{2}-i\frac{\sqrt{2}}{2}\right)$

$=-x\sqrt{2}\left(\cos\frac{5\pi}{4}+i\sin\frac{5\pi}{4}\right)$

$\Rightarrow \arg(Z)=\frac{5\pi}{4}+2k\pi$; $k\in\mathbb{Z}$ (1pt)

• បើ $x=0 \Rightarrow Z=0$

$\Rightarrow \arg(Z)=2k\pi$; $k\in\mathbb{Z}$ (1pt)

(ពិន្ទុ 5) 6. បើ $\arg(Z)=\frac{\pi}{4}+2k\pi$; $k\in\mathbb{Z}$ នោះ $x=y$ ពិត (1pt)

ព្រោះថា

$Z=|Z|\left(\cos\frac{\pi}{4}+i\sin\frac{\pi}{4}\right)$ (1pt)

$=\frac{|Z|}{\sqrt{2}}+\frac{|Z|}{\sqrt{2}}i$ (1pt)

តែ $Z=x+iy$ (1pt)

$\Rightarrow x=y=\frac{|Z|}{\sqrt{2}}$ (1pt)

(ពិន្ទុ 4) 7. បើ $Z=\frac{1}{\bar{Z}}$ នោះ $x=0$ ឬ $y=0$

$Z\neq 0$ ពិត (1pt)

ព្រោះថា

បើ $Z=\frac{1}{\bar{Z}} \Leftrightarrow Z^2=1$ (1pt)

$Z=\pm 1$ (1pt)

Z ជាចំនួនពិត

នោះ $y=0$ ។ (1pt)

លំហាត់ទី II (45 ពិន្ទុ)

(ពិន្ទុ 11) 1.

(3 ពិន្ទុ) a. គណនា $\lim\limits_{x\to+\infty} f_1(x)$

$\lim\limits_{x\to+\infty}\left[2x-2+\ln(x^2+1)\right]=+\infty$ (1pt)

ព្រោះ: $\lim\limits_{x\to+\infty}\ln(x^2+1)=+\infty$ (1pt)

$\lim\limits_{x\to+\infty}(2x-2)=+\infty$ (1pt)

(4 ពិន្ទុ) b. គណនា $f_1'(x)$

$f_1(x)=2x-2+\ln(x^2+1)$

$f_1'(x)=2+\frac{(x^2+1)'}{x^2+1}$ (2pt)

$=2+\frac{2x}{x^2+1}$ (2pt)

(4ពិន្ទុ) c. សង់តារាងអថេរភាពនៃ f_1

$$f_1'(x) = 2 + \frac{2x}{x^2+1}$$

ចំពោះគ្រប់ $x \in [0;+\infty)$; $f'(x) > 0$ (1pt)

នាំឲ្យ: f_1 ជាអនុគមន៍កើនលើ $[0;+\infty)$

$f_1(0) = -2$

x	$0 \qquad\qquad +\infty$
$f_1'(x)$	$+$
$f_1(x)$	$-2 \nearrow +\infty$

(1pt) (1pt) (1pt)

(15ពិន្ទុ) 2. $f_n(x) = 2x - 2 + \frac{\ln(x^2+1)}{n}$; $n \in \mathbb{N}$

(ពិន្ទុ3) a. គណនា $\lim\limits_{x\to+\infty} f_n(x)$

$$\lim_{x\to+\infty} f_n(x) = \lim_{x\to+\infty}\left[2x - 2 + \frac{\ln(x^2+1)}{n}\right] = +\infty \quad (1pt)$$

ព្រោះ: $\lim\limits_{x\to+\infty} \frac{\ln(x^2+1)}{n} = +\infty$ (1pt)

$\lim\limits_{x\to+\infty} (2x-2) = +\infty$ (1pt)

(ពិន្ទុ4) b. បង្ហាញថាអនុគមន៍ f_n កើនលើ $[0;+\infty)$

$$f_n(x) = 2x - 2 + \frac{\ln(x^2+1)}{n}$$

$$f_n'(x) = 2 + \frac{2x}{n(x^2+1)} \quad (2pt)$$

$\forall x \geq 0,\ n \in \mathbb{N} \Rightarrow f_n'(x) > 0$ (1pt)

សន្និដ្ឋាន: អនុគមន៍ $f_n(x)$ កើនដាច់ខាតលើ $[0;+\infty)$ (1pt)

(ពិន្ទុ4) c. បង្ហាញថាសមីការ $f_n(x) = 0$ មានឬសតែមួយគត់ α_n លើ $[0;+\infty)$

មាន $f_n(x)$ កើនដាច់ខាត និងជាប់ លើ $[0;+\infty)$ (1pt)

$f_n(0) = 2(0) - 2 + \frac{\ln 1}{n} = -2$ (1pt)

$\lim\limits_{x\to+\infty} f_n(x) = +\infty$ (1pt)

សន្និដ្ឋាន: $f_n(x) = 0$ មានឬស α_n តែមួយគត់ លើ $[0;+\infty)$ (1pt)

(ពិន្ទុ4) d: បង្ហាញថា $\forall n \in \mathbb{N}$; $0 < \alpha_n < 1$

$f_n(x) = 2x - 2 + \frac{\ln(x^2+1)}{n}$

$f_n(0) = -2$

$f_n(1) = 2 - 2 + \frac{\ln 2}{n} = \frac{\ln 2}{n} > 0$ (1pt)

$f_n(x)$ ជាប់និងកើនដាច់ខាតលើ $[0;1]$ (1pt)

និង $f_n(0)\cdot f_n(1) = -2\cdot\frac{\ln 2}{n} < 0$ (1pt)

មាន α_n តែមួយគត់ ដែល $0 < \alpha_n < 1$; $f_n(\alpha_n) = 0$ (1pt)

(ពិន្ទុ8) 3. បង្ហាញថា $\forall n \in \mathbb{N}$; $f_n(\alpha_{n+1}) > 0$

$$f_{n+1}(\alpha_{n+1}) = 2\alpha_{n+1} - 2 + \frac{\ln(\alpha_{n+1}^2+1)}{n+1} = 0 \quad (1) \quad (2pt)$$

$$f_n(\alpha_{n+1}) = 2\alpha_{n+1} - 2 + \frac{\ln(\alpha_{n+1}^2+1)}{n} \quad (2) \quad (2pt)$$

$$(2)-(1): f_n(\alpha_{n+1}) - 0 = \left(\frac{1}{n} - \frac{1}{n+1}\right)\ln(\alpha_{n+1}^2+1) \quad (2pt)$$

$$= \frac{1}{n(n+1)}\ln(\alpha_{n+1}^2+1) > 0 \quad (1pt)$$

សន្និដ្ឋាន: $f_n(\alpha_{n+1}) > 0$; $\forall n \in \mathbb{N}$ (1pt)

(ពិន្ទុ11) 4. សិក្សាពីស្វ៊ីត (α_n)

(ពិន្ទុ3): a. បង្ហាញថា (α_n) ជាស្វ៊ីតកើន

តាមសំណួរ3) $f_n(\alpha_n) = 0$, $\forall n \in \mathbb{N}$

$f_n(\alpha_{n+1}) > 0$, $\forall n \in \mathbb{N}$

$\Rightarrow f_n(\alpha_{n+1}) > f_n(\alpha_n)$ (1pt)

និង f_n ជាអនុគមន៍កើនលើ $[0;+\infty)$ (1pt)

$\Rightarrow \alpha_{n+1} > \alpha_n$, $\forall n \in \mathbb{N}$ (1pt)

សន្និដ្ឋាន: (α_n) ជាស្វ៊ីតកើន ។

(ពិន្ទុ3) b. ទាញថាស្វ៊ីត (α_n) ជាស្វ៊ីតរួម

ដោយ (α_n) ជាស្វ៊ីតកើនលើ $(0;1)$ (1pt)

និង $\alpha_n < 1$ $\forall n \in \mathbb{N}$ (1pt)

$\Rightarrow (\alpha_n)$ ជាស្វ៊ីតរួម (1pt)

(ពិន្ទុ5) c. គណនា $\lim\limits_{n\to+\infty} \alpha_n$

ដោយ $\alpha_n = 1 - \frac{\ln(\alpha_n^2+1)}{2n}$

នាំឲ្យ: $\lim\limits_{n\to+\infty} \alpha_n = \lim\limits_{n\to+\infty}\left[1 - \frac{\ln(\alpha_n^2+1)}{2n}\right] = 1$ (2pt)

, ព្រោះ: $\lim\limits_{n\to+\infty} \frac{\ln(\alpha_n^2+1)}{2n} = 0$; $\alpha_n \in (0;1)$ (2pt)

សន្និដ្ឋាន: $\lim\limits_{n\to+\infty} \alpha_n = 1$ (1pt)

របៀបទី2 $\alpha_n = 1 - \frac{\ln(\alpha_n^2+1)}{2n}$

ដោយ $0<\alpha_n<1 \Rightarrow 1<\alpha_n^2+1<2$ (1pt)

$0<\frac{\ln(\alpha_n^2+1)}{2n}<\frac{1}{n}$ (1pt)

$\Rightarrow \lim\limits_{n\to+\infty}\frac{\ln(\alpha_n^2+1)}{2n}=0$ (ព្រោះ: $\lim\limits_{n\to+\infty}\frac{1}{n}=0$) (2pt)

ដូចនេះ: $\lim\limits_{n\to+\infty}\alpha_n = 1$ (1pt)

(15ពិន្ទុ) III (5ពិន្ទុ) 1. ស្រាយបញ្ជាក់ថាប្លង់ P និង Q មិនស្របគ្នា

របៀបទី1: $(P): 2x-4y+3z+5=0$ មាន $\vec{n}_1=(2;-4;3)$ (1pt)

$(Q): x-2y+3z-2=0$ មាន $\vec{n}_2=(1;-2;3)$ (1pt)

ដោយ $\frac{2}{1}\neq\frac{3}{3} \Rightarrow \vec{n}_1$ និង $\vec{n}_2$ មិនកូលីនេអ៊ែរ (2pt)

ដូចនេះ: ប្លង់ P និង Q មិនស្របគ្នា (1pt)

របៀបទី2 $P: 2x-4y+3z+5=0$ មាន $\vec{n}_1(2;-4;3)$ (1pt)

$Q: x-2y+3z-2=0$ មាន $\vec{n}_2(1;-2;3)$ (1pt)

$$\vec{n}_1\times\vec{n}_2=\begin{vmatrix}\vec{i}&\vec{j}&\vec{k}\\2&-4&3\\1&-2&3\end{vmatrix}=-6\vec{i}-3\vec{j}+0\vec{k}\neq\vec{0} \quad (2pt)$$

ដូចនេះប្លង់ Q និង P មិនស្របគ្នា (1pt)

(5ពិន្ទុ) 2. រកសមីការប៉ារ៉ាម៉ែតនៃបន្ទាត់ប្រសព្វ D

របៀបទី1 $\begin{cases}2x-4y+3z+5=0\\x-2y+3z-2=0\end{cases}$ (1pt)

តាង $y=t \Rightarrow \begin{cases}2x+3z=4t-5 & (1)\\x+3z=2t+2 & (2)\end{cases}$ (1pt)

$(1)-(2): x=-7+2t$ (1pt)

តាម (2): $-7+2t+3z=2t+2$

$z=3$ (1pt)

ដូចនេះ: $D: \begin{cases}x=-7+2t\\y=t\\z=3\end{cases} (t\in\mathbb{R})$ (1pt)

របៀបទី2

ដោយ $P\cap Q=D$

$\Rightarrow \vec{u}=\vec{n}_1\times\vec{n}_2=(-6;-3;0)$ ជាវ៉ិចទ័រប្រាប់ទិសនៃ D (2pt)

D កាត់តាម $(-7;0;3)$ (2pt)

គេបាន សមីការប៉ារ៉ាម៉ែតនៃ D: $\begin{cases}x=-7-6t\\y=-3t\\z=3\end{cases} (t\in\mathbb{R})$ (1pt)

របៀបទី3 តាង $x=t$ យើងបាន

$\begin{cases}2t-4y+3z+5=0 & (1)\\t-2y+3z-2=0 & (2)\end{cases}$ (1pt)

$(1)-(2): t-2y+7=0 \Rightarrow y=\frac{7+t}{2}$ (1pt)

$(2): t-7-t+3z-2=0 \Rightarrow z=3$ (2pt)

ដូចនេះ: $\begin{cases}x=t\\y=\frac{7}{2}+\frac{1}{2}t\\z=3\end{cases} (t\in\mathbb{R})$ (1pt)

(5ពិន្ទុ) 3. រកសមីការប្លង់ R

ដោយ $R\perp P$
$R\perp Q$

នោះ $R\perp D$ (1pt)

គេបាន $\vec{u}=\vec{n}_1\times\vec{n}_2=(-6;-3;0)$

ជាវ៉ិចទ័រណរម៉ាល់នៃ R (2pt)

ដូចនេះ: $R: 2x+y-2=0$ (2pt)

IV (10ពិន្ទុ)

(5ពិន្ទុ) គណនា $\lim\limits_{n\to+\infty}V_n=\lim\limits_{n\to+\infty}(n+n\cos^2 n)$

ដោយ $n\cos^2 n>0\ \forall n\in\mathbb{N}$ (1pt)

នោះ: $n+n\cos^2 n>n, \forall n$ (1pt)

តែ $\lim\limits_{n\to+\infty}n=+\infty$ នោះ: $\lim\limits_{n\to+\infty}(n+\cos^2 n)=+\infty$ (2pt)

ដូចនេះ: $\lim\limits_{n\to+\infty}V_n=+\infty$ (1pt)

(5ពិន្ទុ) គណនា $\lim\limits_{n\to+\infty}W_n=\lim\limits_{n\to+\infty}\frac{\sin n}{n}$

ដោយ $-1\leq\sin n\leq 1\ \forall n\in\mathbb{N}$ (1pt)

នោះ: $-\frac{1}{n}\leq\frac{\sin n}{n}\leq\frac{1}{n}$ (1pt)

តែ $\lim\limits_{n\to+\infty}-\frac{1}{n}=\lim\limits_{n\to+\infty}\frac{1}{n}=0$ (2pt)

ដូចនេះ: $\lim\limits_{n\to+\infty}W_n=0$ (1pt)

ថ្ងៃទី26 ខែមេសា ឆ្នាំ2015

កាត់ត្រាដោយ ឡុយ វិរៈរ័ត្ន

ឡុយ វិរៈរ័ត្ន

26/04/2015

គណៈកម្មការ និងវិភាគ

ចំណាត់ថ្នាក់ពិន្ទុ

ហ៊ុំ សិលា

3

ប្រឡងជ្រើសរើសសិស្សពូកែទូទាំងប្រទេស

ផ្នែកអក្សរសិល្ប៍ខ្មែរ គណិតវិទ្យា រូបវិទ្យា ថ្នាក់ទី ៩ និងទី ១២

សម័យប្រឡង: ២៥-០៤-២០១៧

វិញ្ញាសា គណិតវិទ្យា ថ្នាក់ទី ១២ ថ្ងៃទី ១ ថ្ងៃទី ២៥-០៤-២០១៧

រយៈពេល ១៨០នាទី ពិន្ទុ ១០០

I. (១៥ពិន្ទុ) នៅក្នុងសំណុំចំនួនពិត $\mathbb{R}$ គេមាន k ដែល $0 < k < 1$ និងស្វីត u កំណត់ដោយ $u_0 = 1$ និងចំពោះគ្រប់ $n \in \mathbb{N}, u_{n+1} = (1+k^n)u_n$ ។

1. ស្រាយបំភ្លឺដោយប្រើវិចារអនុមានរួមគណិតវិទ្យាថាចំពោះគ្រប់ចំនួនគត់ធម្មជាតិ $n \geq 1$; $u_n = (1+k)(1+k^2)(1+k^3)\ldots\ldots(1+k^{n-1})$ ។
2. ចំពោះគ្រប់ $n \in \mathbb{N}, v_n = l_n(u_n)$ បញ្ជាក់(l_n ជាអនុគមន៍លោការីតនេពែ)
   a. បង្ហាញថា ចំពោះគ្រប់ចំនួនពិត $x \geq 0$ គេបាន $l_n(1+x) \leq x$ ។
   b. ទាញបង្ហាញថាស្វីត v ជានិច្ចតូចជាង $\dfrac{k}{1-k}$ ។

II. (១៥ពិន្ទុ) 1. ស្រាយបំភ្លឺថាចំពោះគ្រប់ចំនួនពិត x, គេបាន $1 \leq 2-\cos x \leq 3$ រួច $\dfrac{1}{3} \leq \dfrac{1}{2-\cos x} \leq 1$ ។

2. f ជាអនុគមន៍កំណត់លើ $(0;+\infty)$ ដោយ $f(x) = \dfrac{2-\cos x}{x}$ រកលីមីត $\lim\limits_{x\to+\infty} f(x)$ ។

3. g ជាអនុគមន៍កំណត់លើ $\mathbb{R}$ ដោយ $g(x) = \dfrac{x}{2-\cos x}$ រកលីមីត $\lim\limits_{x\to+\infty} g(x)$ និង $\lim\limits_{x\to-\infty} g(x)$ ។

III. (២០ពិន្ទុ) ABC ជាត្រីកោណសាមញ្ញ ដែលមានកំពស់ AD, BE និង CF ។ស្រាយបំភ្លឺថាបរិមាត្រនៃត្រីកោណ DEF មិនធំជាងពាក់កណ្ដាលបរិមាត្ររបស់ត្រីកោណ ABC ។

IV. (២៥ពិន្ទុ) គេមានស្វីត (u_n) កំណត់ដោយ: $u_0 = -1$, $u_1 = \dfrac{1}{2}$ និងចំពោះគ្រប់ចំនួនគត់ធម្មជាតិ n, $u_{n+2} = u_{n+1} - \dfrac{1}{4}u_n$ ។

1. គណនា u_2 និងសិក្សាថាតើ (u_n) ជាស្វីតនព្វន្តឬទេ?តើ (u_n) ជាស្វីតធរណីមាត្រឬទេ?
2. គេកំណត់ (v_n) ដោយចំពោះគ្រប់ $n: v_n = u_{n+1} - \dfrac{1}{2}u_n$

   គណនា v_0 ។ សរសេរ v_{n+1} ជាអនុគមន៍នៃ v_n និងសរសេរ v_n ជាអនុគមន៍នៃ n ។
3. គេកំណត់ (w_n) ដោយចំពោះគ្រប់ $n: w_n = \dfrac{u_n}{v_n}$

   a. គណនា w_0 រួចបង្ហាញថាចំពោះគ្រប់ n នៃ $\mathbb{N}$, $w_{n+1} = w_n + 2$ ។

   b. សរសេរ w_n ជាអនុគមន៍នៃ n ។
4. បង្ហាញថាចំពោះគ្រប់ចំនួនគត់ធម្មជាតិ $n: u_n = \dfrac{2n-1}{2^n}$ ។
5. ចំពោះគ្រប់ចំនួនគត់ធម្មជាតិ n គេតាង $s_n = \sum\limits_{i=0}^{n} u_i = u_0 + u_1 + \ldots\ldots + u_n$ ស្រាយបំភ្លឺថាចំពោះគ្រប់ n នៃ $\mathbb{N}$, $s_n = 2 - \dfrac{2n+3}{2^n}$ ។

V. (១៥ពិន្ទុ) គេមាន $x_1, x_2, \ldots, x_5$ ជាចំនួនពិតវិជ្ជមានដែលផ្ទៀងផ្ទាត់ $\sum\limits_{i=1}^{5} \dfrac{1}{1+x_i} = 1$ ។ បង្ហាញថា $\sum\limits_{i=1}^{5} \dfrac{x_i}{4+x_i^2} \leq 1$ ។

VI. (១០ពិន្ទុ) យើងមាន $f(x)$ កំណត់លើ $\mathbb{R}$ ដោយ $f(1) = 1$ និងចំពោះគ្រប់ $x \in \mathbb{R}$; $f(x+5) \geq f(x) + 5$ និង $f(x+1) \leq f(x) + 1$ ។ គេមាន $g(x) = f(x) + 1 - x$ ។ ចូរកំណត់ $g(2017)$ ។

ចម្លើយកែវិញ្ញាសា គណិតវិទ្យាថ្នាក់ទី ១២

ថ្ងៃទី១ ថ្ងៃទី២៦ . ០៤ . ២០១៧

រយៈពេល ១៥០ នាទី ពិន្ទុ ១០០

I.(១៥ពិន្ទុ)

1. ស្រាយបញ្ជាក់ថា: $U_n = (1+k)\cdot(1+k^2)\cdots(1+k^{n-1})$

ចំពោះ $n=1$ ពិតហើយ

$U_n = (1+k)(1+k^2)\cdots(1+k^{n-2})(1+k^{n-1})$

ដូចនេះពិតជានិច្ច (5pt)

2. a. បង្ហាញថា $\ln(1+x) \leq x \ , \ x \geq 0$

តាង $f(x) = \ln(1+x) - x$

យើងបាន: $f'(x) = \frac{(1+x)'}{(1+x)} - 1$ (1pt)

$= \frac{1}{1+x} - 1 = -\frac{x}{1+x} \leq 0$

ព្រោះ $x \geq 0$ (1pt)

$\Rightarrow f$ ជាអនុគមន៍ចុះលើ $[0, +\infty)$

$\Rightarrow f(x) \leq f(0)$ (1pt)

$\Rightarrow \ln(1+x) - x \leq \ln(1+0) - 0$

$\Rightarrow \ln(1+x) - x \leq 0$ (1pt)

ដូចនេះ: $\boxed{\ln(1+x) \leq x \ , \ \forall x \geq 0}$ (1pt)

b. ចូរបង្ហាញថា $V_n < \frac{k}{1-k} \ , \forall n$

(5pt)

II. (១២ពិន្ទុ)

1. ស្រាយបញ្ជាក់ថា $1 \le 2-\cos x \le 3$ និង $\frac{1}{3} \le \frac{1}{2-\cos x} \le 1$

គេបាន $-1 \le \cos x \le 1,\ \forall x \in \mathbb{R}$ (1pt)

$\Rightarrow 1 \ge -\cos x \ge -1\ \ \forall x \in \mathbb{R}$, (1pt)

$\Rightarrow 3 \ge 2-\cos x \ge 1,\ \forall x \in \mathbb{R}$, (1pt)

$\Rightarrow \frac{1}{3} \le \frac{1}{2-\cos x} \le 1,\ \forall x \in \mathbb{R}$, (1pt)

ដូចនេះ $1 \le 2-\cos x \le 3$

$\boxed{\text{និង } \frac{1}{3} \le \frac{1}{2-\cos x} \le 1,\ (\forall x \in \mathbb{R})}$ (1pt)

2. គណនា $\lim\limits_{x\to+\infty} f(x)$

យើងមាន: $1 \le 2-\cos x \le 3$ (1pt)

$\frac{1}{x} \le \frac{2-\cos x}{x} \le \frac{3}{x},\ \forall x>0$

នាំ $\frac{1}{x} \le f(x) \le \frac{3}{x}$ (1pt)

ដោយ $\lim\limits_{x\to+\infty} \frac{1}{x} = 0$ (1pt)

$\lim\limits_{x\to+\infty} \frac{3}{x} = 0$ (1pt)

ដូចនេះ

$$\boxed{\lim_{x\to+\infty} f(x) = 0}$$

3. គណនា $\lim\limits_{x\to+\infty} g(x)$ និង $\lim\limits_{x\to-\infty} g(x)$

យើងមាន: $\frac{1}{3} \le \frac{1}{2-\cos x} \le 1$

- ករណី $x>0$: $\frac{x}{3} \le \frac{x}{2-\cos x} \le x$ (1pt)

$\frac{x}{3} \le g(x)$

ដោយ $\lim\limits_{x\to+\infty} \frac{x}{3} = +\infty$ (1pt)

ដូចនេះ $\boxed{\lim\limits_{x\to+\infty} g(x) = +\infty}$ (1pt)

+ ករណី $x<0$: $\frac{x}{3} \ge \frac{x}{2-\cos x} \ge x$ (1pt)

$\frac{x}{3} \ge g(x) \ge x$

ដោយ $\lim\limits_{x\to-\infty} \frac{x}{3} = -\infty$ (1pt)

ដូចនេះ $\boxed{\lim\limits_{x\to-\infty} g(x) = -\infty}$ (1pt)

III (២០ពិន្ទុ)



(2pt)

ស្រាយបញ្ជាក់ថា $DE + EF + FD \le \frac{1}{2}(AB + BC +$

យើងមាន $\angle ADB = \angle AEB = 90^\circ$

នាំឲ្យចំណុច A, B, D, E នៅលើរង្វង់ដែលមានអង្កត់ផ្ចិត AB ។ (1pt)

តាមទ្រឹស្តីបទស៊ីនុសចំពោះ ΔADE

គេបាន $\frac{DE}{\sin \angle DAE} = AB$

$\Rightarrow DE = AB \sin \angle DAE$ (1pt)

$= AB \cos C$ (ព្រោះ ΔDAC កែងត្រង់ D (1pt)

+ $\angle ADC = \angle AFC = 90^\circ$

$\Rightarrow$ ចំណុច A, F, D, C នៅលើរង្វង់អង្កត់ផ្ចិត (1

តាមទ្រឹស្តីបទស៊ីនុសចំពោះ ΔADF

គេបាន $\frac{DF}{\sin \angle DAF} = AC$

$DF = AC.\sin \angle DAF$ (1pt)

$= AC \cos B$ (ព្រោះ ΔADB កែងត្រង់ D (1p

គេបាន $DE + DF = AB\cos C + AC \cos B$ (1) (1p

ចំពោះ $AB = 2R\sin C$, $AC = 2R\sin B$

(ទ្រឹស្តីបទស៊ីនុសចំពោះ ΔABC ចារឹកក្នុងរង្វង់

តាម(1) $DE + DF = 2R\sin C\cos C + 2R\sin B\cos B$ (1pt)

$= R(\sin 2C + \sin 2B)$ (1pt)

$= 2R\sin(B+C).\cos(B-C)$ (1pt)

$= 2R\sin A.\cos(B-C)$

$= AB.\cos(B-C)$ (1pt)

$DE + DF = AB\cos(B-C) \leq AB$ (i) (1pt)

តាមលំនាំដូចគ្នា $ED + EF \leq CA$ (ii) (2pt)

$FD + FE \leq BC$ (iii) (2pt)

បូកអង្គនិងអង្គ (i), (ii) និង (iii) គេបាន

$2(DE + EF + FD) \leq AB + BC + CA$ (1pt)

ដូចនេះ $\boxed{DE + EF + FD \leq \frac{1}{2}(AB + BC + CA)}$ (1pt)

IV. (២៥ពិន្ទុ) $U_0 = -1$, $U_1 = \frac{1}{2}$, $U_{n+2} = U_{n+1} - \frac{1}{4}U_n$

1. គណនា U_2

គេបាន $U_2 = U_1 - \frac{1}{4}U_0$

$= \frac{1}{2} - \frac{1}{4}(-1) = \frac{1}{2} + \frac{1}{4} = \frac{3}{4}$ (1pt)

$\boxed{U_2 = \frac{3}{4}}$

សិក្សាស៊ីត (U_n)

+ $U_1 - U_0 = \frac{1}{2} - (-1) = \frac{3}{2}$

$U_2 - U_1 = \frac{3}{4} - \frac{1}{2} = \frac{1}{4}$

$\Rightarrow U_1 - U_0 \neq U_2 - U_1$ (1pt)

ដូចនេះ $\boxed{(U_n) \text{ មិនមែនជាស៊ីតនព្វន្តទេ}}$ (1pt)

+ $\frac{U_1}{U_0} = \frac{\frac{1}{2}}{-1} = -\frac{1}{2}$

$\frac{U_2}{U_1} = \frac{3/4}{1/2} = \frac{3}{2}$

$\Rightarrow \frac{U_1}{U_0} \neq \frac{U_2}{U_1}$ (1pt)

ដូចនេះ $\boxed{(U_n) \text{ មិនមែនជាស៊ីតធរណីមាត្រទេ}}$ (1pt)

2. គណនា V_0

គេបាន $V_n = U_{n+1} - \frac{1}{2}U_n$

$V_0 = U_1 - \frac{1}{2}U_0 = \frac{1}{2} - \frac{1}{2}(-1) = 1$

ដូចនេះ $\boxed{V_0 = 1}$ (1pt)

ស្រាយថា V_{n+1} ជាអនុគមន៍នៃ V_n

$V_n = U_{n+1} - \frac{1}{2}U_n$

$V_{n+1} = U_{n+2} - \frac{1}{2}U_{n+1}$ (1pt)

$= U_{n+1} - \frac{1}{4}U_n - \frac{1}{2}U_{n+1}$

$= \frac{1}{2}U_{n+1} - \frac{1}{4}U_n = \frac{1}{2}(U_{n+1} - \frac{1}{2}U_n)$

$= \frac{1}{2}V_n$

ដូចនេះ $\boxed{V_{n+1} = \frac{1}{2}V_n \;,\; \forall n}$ (1pt)

ស្រាយថា V_n ជាអនុគមន៍នៃ n

ដោយគេមាន $V_{n+1} = \frac{1}{2}V_n$, $\forall n$

$\Rightarrow (V_n)$ ជាស៊ីតធរណីមាត្រដែលមានតួទី1 $V_0 = 1$

និង ផលធៀបរួម $q = \frac{1}{2}$ (1pt)

$\Rightarrow V_n = V_0 . q^n = 1.(\frac{1}{2})^n = \frac{1}{2^n}$ (1pt)

ដូចនេះ $\boxed{V_n = \frac{1}{2^n}}$

3. a គណនា W_0

$W_0 = \frac{U_0}{V_0} = \frac{-1}{1} = -1$ (1pt)

ដូចនេះ $\boxed{W_0 = -1}$

បង្ហាញថា $W_{n+1} = W_n + 2$, $\forall n$

ដោយគេមាន $W_{n+1} = \frac{U_{n+1}}{V_{n+1}}$

តែ $V_n = U_{n+1} - \frac{1}{2}U_n \Rightarrow U_{n+1} = V_n + \frac{1}{2}U_n$

$\Rightarrow W_{n+1} = \frac{V_n + \frac{1}{2}U_n}{\frac{1}{2}V_n} = 2 + W_n$ (1pt)

ដូចនេះ $\boxed{W_{n+1} = W_n + 2 \;,\; \forall n}$ (1pt)

3

៦. ស្វែងរក w_n ជាអនុគមន៍នៃ n

យើងបាន $w_{n+1} = w_n + 2$

$\Rightarrow (w_n)$ ជាស្វ៊ីតនព្វន្តដែលមានតួទី ១ $w_0 = -1$, និងផលសងរួម $d = 2$ (1pt)

$\Rightarrow w_n = w_0 + nd = -1 + 2n$

ដូចនេះ: $\boxed{w_n = 2n - 1 \ , \ \forall n}$ (1pt)

៧. បង្ហាញថា $U_n = \frac{2n-1}{2^n}$, $\forall n$

យើងបាន: $w_n = \frac{U_n}{v_n}$

$\Rightarrow U_n = w_n \times v_n = \frac{2n-1}{2^n}$ (3pt)

ដូចនេះ: $\boxed{U_n = \frac{2n-1}{2^n} \ , \ \forall n}$ (2pt)

៨. ស្រាយបញ្ជាក់ថា $S_n = 2 - \frac{2n+3}{2^n}$, $\forall n$

យើងបាន $S_n = \sum_{i=0}^{n} U_i$

$= U_0 + U_1 + U_2 + \dots + U_n$

$= -1 + \frac{1}{2} + \frac{3}{2^2} + \dots + \frac{2n-1}{2^n}$ (1pt)

$\frac{1}{2} S_n = -\frac{1}{2} + \frac{1}{2^2} + \frac{3}{2^3} + \dots + \frac{2n-1}{2^{n+1}}$ (1pt)

ដកអង្គនិងអង្គ គេបាន

$\frac{1}{2} S_n = -1 + 1 + \frac{2}{2^2} + \frac{2}{2^3} + \dots + \frac{2}{2^n} - \frac{2n-1}{2^{n+1}}$ (1pt)

$= 2\left[\frac{1}{4} \cdot \frac{1 - (\frac{1}{2})^{n-1}}{1 - \frac{1}{2}}\right] - \frac{2n-1}{2^{n+1}}$

$= 1 - \frac{1}{2^{n-1}} - \frac{2n-1}{2^{n+1}}$ (1pt)

$= 1 - \frac{4 + 2n - 1}{2^{n+1}}$

ដូចនេះ: $\boxed{S_n = 2 - \frac{2n+3}{2^n}}$ (1pt)

V (១៥ពិន្ទុ) បង្ហាញថា $\sum_{i=1}^{5} \frac{x_i}{4 + x_i^2} \le 1$

គេមាន $x_1, x_2, \dots, x_5$ ជាចំនួនពិតវិជ្ជមាន ដែលផ្ទៀងផ្ទាត់ $\sum_{i=1}^{5} \frac{1}{1+x_i} = 1$

តាង $y_i = \frac{1}{1+x_i} \Leftrightarrow x_i = \frac{1-y_i}{y_i}$ (1pt)

$\Rightarrow \sum_{i=1}^{5} y_i = 1$ (1pt)

គេបាន $\sum_{i=1}^{5} \frac{x_i}{4 + x_i^2} = \sum_{i=1}^{5} \frac{\frac{1-y_i}{y_i}}{4 + \frac{(1-y_i)^2}{y_i^2}}$ (2pt)

$= \sum_{i=1}^{5} \frac{y_i(1-y_i)}{5y_i^2 - 2y_i + 1}$ (2pt)

$= \sum_{i=1}^{5} -\frac{1}{5} \frac{5y_i^2 - 2y_i + 1 - 3y_i - 1}{5y_i^2 - 2y_i + 1}$ (1pt)

$= -\frac{1}{5} \sum_{i=1}^{5} \left(1 - \frac{3y_i + 1}{5y_i^2 - 2y_i + 1}\right)$ (1pt)

$= -1 + \frac{1}{5} \sum_{i=1}^{5} \frac{3y_i + 1}{5(y_i - \frac{1}{5})^2 + \frac{4}{5}}$ (2pt)

$\le -1 + \frac{1}{5} \sum_{i=1}^{5} \frac{3y_i + 1}{4/5}$ (ព្រោះ: $(y_i - \frac{1}{5})^2 \ge 0$)

$\le -1 + \frac{3}{4} \sum_{i=1}^{5} y_i + \frac{5}{4}$ (1pt)

$\le -1 + \frac{3}{4} + \frac{5}{4}$

≤ 1 (1pt)

ដូចនេះ: $\boxed{\sum_{i=1}^{5} \frac{x_i}{4 + x_i^2} \le 1}$ (1pt)

VI. (១០ពិន្ទុ) ចូរគណនា $g(2017)$

យើងមាន: $\begin{cases} f(x+5) \ge f(x) + 5 \ , \ f(1) = 1 \\ f(x+1) \le f(x) + 1 \end{cases}$

គេបាន $f(x) + 5 \le f(x+5)$

$\le f[(x+4)+1] \le f(x+4) + 1$

(ព្រោះ: $f(x+1) \le f(x) + 1$) (1pt)

$\leq f[(x+3)+1]+1 \leq$

$\leq f[x+3]+2 \leq$ (1pt)

$\leq f(x+2)+3 \leq$

$\leq f(x+1)+4 \leq$ (1pt)

$\leq f(x)+5$

$\Rightarrow f(x)+5 \leq f(x+5) \leq f(x+1)+4 \leq f(x)+5$ (1pt)

$\Rightarrow f(x)+5 = f(x+5) = f(x+1)+4$ (1pt)

$\Rightarrow f(x)+5 = f(x+1)+4$

$\Rightarrow f(x+1) = f(x)+1$ (1pt)

ដោយ $f(1) = 1$

$\Rightarrow f(2) = 2$

$f(3) = 3$

$------$

$f(2017) = 2017$ (2pt)

តែ $g(x) = f(x)+1-x$

$\Rightarrow g(2017) = f(2017)+1-2017$ (1pt)

ដូចនេះ: $\boxed{g(2017) = 1}$ (1pt)

ភ្នំពេញថ្ងៃទី25 ខែតុលា ឆ្នាំ2017

អ្នកកត់ ⑥

ទុំ. សីហស៊ី

បានឃើញ និងឯកភាព

ប្រធានក្រុមកិច្ចការ

ស៊ី សាវឿ

អនុប្រធាន

សៅ ឈឹមគ្រឹ ⑤

ប្រឡងជ្រើសរើសសិស្សពូកែទូទាំងប្រទេស
ផ្នែកអក្សរសិល្ប៍ខ្មែរ គណិតវិទ្យា រូបវិទ្យា ថ្នាក់ទី ៩ និងទី ១២
សម័យប្រឡងៈ ២៥-០៤-២០១៧
វិញ្ញាសា គណិតវិទ្យា ថ្នាក់ទី ១២ ថ្ងៃទី ៣ ថ្ងៃទី ២៧/០៤-២០១៧
រយៈពេល ១៨០នាទី ពិន្ទុ ១០០

I. (១៥ពិន្ទុ) កំណត់តម្លៃចំនួនពិតអវិជ្ជមាន a ដែលវិសមភាព $\sin^2 x + a\cos x + a^2 \ge 1 + \cos x$ ផ្ទៀងផ្ទាត់ចំពោះគ្រប់ $x \in \mathbb{R}$ ។

II. (២៥ពិន្ទុ) គេមាន α និង β ជាឫសរបស់សមីការ $x^2 - x - 1 = 0$ ។គេកំណត់ស្វីត $a_n = \dfrac{\alpha^n - \beta^n}{\alpha - \beta}$, $n = 1, 2, ...$

1. បង្ហាញថាចំពោះគ្រប់ចំនួនគត់ធម្មជាតិមិនសូន្យ n គេបាន $a_{n+2} = a_{n+1} + a_n$ ។
2. រកគ្រប់ចំនួនគត់ធម្មជាតិមិនសូន្យ a និង b ដែល $a < b$ ផ្ទៀងផ្ទាត់ $a_n - 2na^n$ ចែកដាច់នឹង b ចំពោះគ្រប់ចំនួនគត់ធម្មជាតិមិនសូន្យ n ។

III. (២០ពិន្ទុ) គេមានត្រីធាតុនៃចំនួនគត់ធម្មជាតិមិនសូន្យ (x, y, z) និងជារង្វាស់នៃជ្រុងរបស់ត្រីកោណកែងមួយ ។

1. ស្រាយបំភ្លឺថាបើ p ជាចំនួនគត់ធម្មជាតិមិនសូន្យ នោះត្រីធាតុ (px, py, pz) ក៏ជារង្វាស់នៃជ្រុងរបស់ត្រីកោណកែងដែរ ។
2. ស្រាយបំភ្លឺថាបើត្រីធាតុ (x, y, z) ជារង្វាស់នៃជ្រុងរបស់ត្រីកោណកែងនោះចំនួនគត់ធម្មជាតិ x, y និង z មិនអាចជាចំនួនសេសទាំងបីនោះទេ ។
3. ក្នុងសំណួរនេះគេសន្មតថាគ្រប់ចំនួនគត់ធម្មជាតិមិនសូន្យ n អាចសរសេរតែម្យ៉ាងគត់ជារាង $n = 2^\alpha \times k$ ដែល α ជាចំនួនគត់ធម្មជាតិអាចសូន្យនិង k ជាចំនួនគត់ធម្មជាតិសេស ។
   a. ចូររក α និង k ក្នុងករណី $n = 192$ ។
   b. x និង z ជាចំនួនគត់ធម្មជាតិមិនសូន្យដែល $x = 2^\alpha \times k$ និង $z = 2^\beta \times m$ ។ចូររក α_1 និង k_1 ព្រមទាំង α_2 និង k_2 ដែល $2x^2 = 2^{\alpha_1} \times k_1$ និង $z^2 = 2^{\alpha_2} \times k_2$ ។
   c. បង្ហាញថាគ្មានគូចំនួនគត់ធម្មជាតិមិនសូន្យ (x, z) ដែល $2x^2 = z^2$ ។

IV. (១៥ពិន្ទុ) 1. គេមានអនុគមន៍ f កំណត់លើ $(0; +\infty)$ ដោយ $f(x) = \dfrac{x}{e^x - 1}$ ។ គណនា $\lim\limits_{x \to 0} f(x)$ និង $\lim\limits_{x \to +\infty} f(x)$ ។

2. គេមានស្វីត (u_n) កំណត់ចំពោះគ្រប់ចំនួនគត់ធំជាងឬស្មើ 1 ដោយ $u_n = \dfrac{1}{n}\left[1 + e^{\frac{1}{n}} + e^{\frac{2}{n}} + ... + e^{\frac{n-1}{n}}\right]$

ស្រាយបំភ្លឺថា $1 + e^{\frac{1}{n}} + e^{\frac{2}{n}} + ... + e^{\frac{n-1}{n}} = \dfrac{1 - e}{1 - e^{\frac{1}{n}}}$ ។ រួចទាញបង្ហាញថា $u_n = (e-1) f\left(\dfrac{1}{n}\right)$ ។

3. ប្រើសំណួរខាងលើរក $\lim\limits_{n \to +\infty} u_n$ ។

V. (២៥ពិន្ទុ) គេមានរង្វង់មួយដែលមានផ្ចិត 0 និង P ជាចំណុចនៅក្រៅរង្វង់ ។ PA និង PB ជាបន្ទាត់ប៉ះគូសចេញពី P ទៅប៉ះរង្វង់ផ្ចិត 0 ត្រង់ A និង B ។ PD ជាបន្ទាត់កាត់គូសចេញពី P ដែលកាត់រង្វង់ត្រង់ C និង D ។ BF ជាបន្ទាត់ស្របនឹង PA ហើយកាត់បន្ទាត់ AC, AD រៀងគ្នាត្រង់ E និង F ។ ស្រាយបំភ្លឺថា $BE = BF$ ។

ដំណោះស្រាយ វិញ្ញាសា គណិតវិទ្យាថ្នាក់ទី ១២

ថ្ងៃទី ៣ ថ្ងៃទី ២៧.០៥.២០១៧ (វិញ្ញាសាទី២)

រយៈពេល ១៥០ នាទី ពិន្ទុ ១០០

I. (១៥ពិន្ទុ) កំណត់តម្លៃ a

វិសមភាព $\sin^2 x + a\cos x + a^2 \geq 1 + \cos x$

ផ្ទៀងផ្ទាត់ចំពោះគ្រប់ $x \in \mathbb{R}$

នោះផ្ទៀងផ្ទាត់ចំពោះ $x = 0$. (1pt)

. គេបាន $x=0$ វិសមភាពអាចសរសេរ

$a + a^2 \geq 2$ (1pt)

$a^2 + a - 2 \geq 0$

គេបាន $a_1 = 1$, $a_2 = -2$ (1pt)

a	$-\infty$	-2	1	$+\infty$
a^2+a-2	$+$	ϕ $-$	ϕ	$+$ (1pt)

$a^2 + a - 2 \geq 0 \Leftrightarrow a \in (-\infty, -2] \cup [1, +\infty)$ (1pt)

តែ $a < 0 \Rightarrow a \in (-\infty, -2]$ (1pt)

ចំពោះ $a \leq -2$ គេបាន

$\cos x \leq 1$, $\forall x \in \mathbb{R}$ (1pt)

$a\cos x \geq a$, $\forall x \in \mathbb{R}$ (1pt)

$a^2 + a\cos x \geq a^2 + a \geq 2$, $\forall x \in \mathbb{R}$ (1) (1pt)

តែ $2 \geq \cos^2 x + \cos x$, $\forall x \in \mathbb{R}$ (1pt)

$2 \geq 1 - \sin^2 x + \cos x$, $\forall x \in \mathbb{R}$ (2) (1pt)

តាម (1) និង (2) គេបាន:

$a^2 + a\cos x \geq 1 - \sin^2 x + \cos x$, $\forall x \in \mathbb{R}$ (1pt)

$\sin^2 x + a\cos x + a^2 \geq 1 + \cos x$, $\forall x \in \mathbb{R}$ (1pt)

ដូចនេះ: វិសមភាពផ្ទៀងផ្ទាត់ គ្រប់ $x \in \mathbb{R}$ កាលណា $a \in (-\infty, -2]$ (2pt)

II. (២៥ពិន្ទុ)

1. បង្ហាញថា $a_{n+2} = a_{n+1} + a_n$, $\forall n \in \mathbb{N}$

របៀបទី1. យើងបាន

$$a_{n+2} = \frac{\alpha^{n+2} - \beta^{n+2}}{\alpha - \beta} \quad (2pt)$$

$$= \frac{\alpha^{n+2} - \alpha\beta^{n+1} + \alpha^{n+1}\beta - \beta^{n+2} - \alpha^{n+1}\beta + \alpha\beta^{n+1}}{\alpha - \beta} \quad (2pt)$$

$$= \frac{\alpha(\alpha^{n+1} - \beta^{n+1}) + \beta(\alpha^{n+1} - \beta^{n+1}) - \alpha\beta(\alpha^n - \beta^n)}{\alpha - \beta}$$

$$a_{n+2} = \frac{(\alpha^{n+1} - \beta^{n+1})(\alpha + \beta) - \alpha\beta(\alpha^n - \beta^n)}{(\alpha - \beta)} \quad (2pt)$$

តែ α, β ជាឫសនៃសមីការ $x^2 - x - 1 = 0$

$$\Rightarrow \begin{cases} \alpha + \beta = 1 \\ \alpha \cdot \beta = -1 \end{cases} \quad (2pt)$$

$$\Rightarrow a_{n+2} = \frac{\alpha^{n+1} - \beta^{n+1}}{\alpha - \beta} + \frac{\alpha^n - \beta^n}{\alpha - \beta}$$

ដូចនេះ:

$$\boxed{a_{n+2} = a_{n+1} + a_n \ , \ n \in \mathbb{N}} \quad (2pt)$$

របៀបទី2 យើងបាន

α, β ជាឫសសមីការ $x^2 - x - 1 = 0, \alpha \neq \beta$

$$\begin{cases} \alpha^2 - \alpha - 1 = 0 \\ \beta^2 - \beta - 1 = 0 \end{cases} \quad (2pt)$$

$$\begin{cases} \alpha^{n+2} - \alpha^{n+1} - \alpha^n = 0 \\ \beta^{n+2} - \beta^{n+1} - \beta^n = 0 \end{cases} \quad (2pt)$$

ដកអង្គ និង អង្គ

$$(\alpha^{n+2} - \beta^{n+2}) - (\alpha^{n+1} - \beta^{n+1}) - (\alpha^n - \beta^n) = 0 \quad (2pt)$$

ចែកអង្គទាំងពីរនឹង $\alpha - \beta$

$$\frac{\alpha^{n+2} - \beta^{n+2}}{\alpha - \beta} - \frac{\alpha^{n+1} - \beta^{n+1}}{\alpha - \beta} - \frac{\alpha^n - \beta^n}{\alpha - \beta} = 0 \quad (2pt)$$

$$a_{n+2} - a_{n+1} - a_n = 0$$

ដូចនេះ: $\boxed{a_{n+2} - a_{n+1} - a_n = 0}$ (2pt)

2. រកគ្រប់ចំនួនគត់វិជ្ជមាន a និង b

$+$ បើ $b \mid (a_n - 2na^n)$, $\forall n \in \mathbb{N}$

ករណី $n=1$ នោះ $b \mid a_1 - 2a$

ដែល $a_1 = \frac{\alpha-\beta}{\alpha-\beta} = 1$

$\Rightarrow b \mid 1-2a$

$\Rightarrow b = 2a-1$ (ព្រោះ $a<b$) (2pt)

ករណី $n>1$ នោះ

$b \mid (a_n - 2na^n)$, $b \mid (a_{n+1} - 2(n+1)a^{n+1})$

$b \mid (a_{n+2} - 2(n+2)a^{n+2})$

ដោយ $a_{n+2} = a_{n+1} + a_n$

$\Rightarrow b \mid (a_{n+1} + a_n - 2na^n - 2(n+1)a^{n+1})$ (2pt)

$b \mid (a_{n+2} - 2(n+2)a^{n+2} + 2(n+2)a^{n+2} - 2(n+1)a^{n+1} - 2na^n)$

$\Rightarrow b \mid (2(n+2)a^{n+2} - 2(n+1)a^{n+1} - 2na^n)$

ដោយ $\gcd(a,b) = 1$, $b > a$

$\Rightarrow b \mid ((n+2)a^2 - (n+1)a - n)$ (1)

និង $b \mid ((n+3)a^2 - (n+2)a - (n+1))$ (2)

$\Rightarrow b \mid (a^2 - a - 1)$ (2pt)

$\Rightarrow (2a-1) \mid (a^2 - a - 1)$

$(2a-1) \mid (2a^2 - 2a - 2)$

$(2a-1) \mid [a(2a-1) - a - 2]$

$\Rightarrow (2a-1) \mid (-a-2)$

$(2a-1) \mid [-(2a-1) - 5]$

$\Rightarrow (2a-1) \mid 5$ (2pt)

$\Rightarrow \left[\begin{array}{l} 2a-1 = 1 \\ 2a-1 = 5 \end{array}\right. \Rightarrow \left[\begin{array}{l} a = 1 \\ a = 3 \end{array}\right.$

បើ $a=1 \Rightarrow a=b=1$ មិនពិត ($a<b$)

បើ $a=3 \Rightarrow b=5$ (2pt)

⊕ បើ $a=3$, $b=5$ នោះយើងនឹងស្រាយគ្រប់ $n \in \mathbb{N}$ គេបាន

$b \mid (a_n - 2na^n)$ គឺ $5 \mid (a_n - 2n3^n)$

· ចំពោះ $n=1 \Rightarrow 5 \mid (a_1 - 2\times3)$

$5 \mid (-5)$ ពិត (1pt)

· ឧបមាថាពិតដល់ $n=k+1$ គេបាន

$5 \mid (a_k - 2k3^k)$

$5 \mid [a_{k+1} - 2(k+1)3^{k+1}]$ (1pt)

· ស្រាយថាពិតដល់ $n=k+2$

គឺ $5 \mid [a_{k+2} - 2(k+2)3^{k+2}]$

យើងបាន:

$5 \mid (a_{k+1} + a_k - 2(k+1)3^{k+1} - 2k3^k)$

$5 \mid (a_{k+2} - 2\times3^k(3(k+1)+k))$ (1pt)

$5 \mid (a_{k+2} - 2\times3^k(4k+3))$

ដើម្បីឲ្យ $5 \mid (a_{k+2} - 2(k+2)3^{k+2})$

លុះត្រាតែ

$2(k+2)3^2 \equiv 2(4k+3) \pmod 5$

$9k + 18 \equiv 4k + 3 \pmod 5$

$5k + 15 \equiv 0 \pmod 5$

$\Rightarrow 5 \mid (a_{k+2} - 2(k+2)3^{k+2})$ ពិត

ចំពោះ $n=k+2$

សរុបមក: $\boxed{a=3, b=5}$ (2pt)

2

III. (២០ពិន្ទុ)

1. ស្រាយបញ្ជាក់ថា px, py, pz ជាត្រីធាតុពីតាគ័រ

បើគេមាន x, y, z ជាត្រីធាតុពីតាគ័រ

$(x<y<z)$ (1pt)

$\Rightarrow x^2+y^2=z^2$ (1pt)

$p^2x^2+p^2y^2=p^2z^2$

$(px)^2+(py)^2=(pz)^2$ (1pt)

ដូចនេះ: $\boxed{px, py, pz \text{ ជាត្រីធាតុពីតាគ័រ}}$ (1pt)

2. ស្រាយបញ្ជាក់ថា x, y, z មិនអាចជាចំនួនគត់សេសទាំងបី

ឧបមាថា x, y, z ជាចំនួនគត់សេសទាំងបី (1pt)

យើងបាន: x^2+y^2 ជាចំនួនគត់គូ (1pt)

តែ z^2 ជាចំនួនគត់សេស

$\Rightarrow x^2+y^2 \neq z^2$ (ផ្ទុយពីការពិត) (1pt)

ដូចនេះ: x, y, z មិនអាចជាចំនួនគត់សេសទាំងបីទេ (1pt)

3. a. រក α និង k

យើងមាន $n = 2^\alpha \times k$

ចំពោះ $n = 192$

$\Rightarrow 2^\alpha \times k = 192 = 2^6\times 3$ (2pt)

ដូចនេះ: $\boxed{\alpha=6 \ , k=3}$ (2pt)

b. រក α_1 និង k_1 ព្រមទាំង α_2 និង k_2

យើងមាន

$x = 2^\alpha \times k \Rightarrow x^2 = 2^{2\alpha}\times k^2$

ឬ $2x^2 = 2^{2\alpha+1}\times k^2$

ដោយ $2x^2 = 2^{\alpha_1}\times k_1$

$\Rightarrow \begin{cases} \alpha_1 = 2\alpha+1 \\ k_1 = k^2 \end{cases}$ (k ជាចំនួនគត់សេស) (2pt)

ហើយ $z = 2^\beta \times m \Rightarrow z^2 = 2^{2\beta}\times m^2$

ដោយ $z^2 = 2^{\alpha_2}\times k_2$

$\Rightarrow \begin{cases} \alpha_2 = 2\beta \\ k_2 = m^2 \end{cases}$ (2pt)

c. បង្ហាញថា គ្មានគូចំនួនគត់វិជ្ជមាន (x, z) ដែល $2x^2=z^2$

តាមសម្រាយខាងលើ:

$\left.\begin{array}{l} 2x^2 = 2^{2\alpha+1}\times k^2 \\ z^2 = 2^{2\beta}\times m^2 \end{array}\right\}$ (1pt)

$2x^2=z^2 \Leftrightarrow \begin{cases} 2\alpha+1 = 2\beta \\ k^2 = m^2 \end{cases}$ (2pt)

(ផ្ទុយពីការពិត)

ដូចនេះ: $\boxed{\text{គ្មានគូ } (x, z) \text{ ដែល } 2x^2=z^2 \text{ ទេ}}$ (1pt)

IV. (១៥ពិន្ទុ)

1. គណនា $\lim\limits_{x\to 0^+} f(x)$ និង $\lim\limits_{x\to +\infty} f(x)$

មាន $f(x) = \dfrac{x}{e^x-1}$ កំណត់លើ $(0, +\infty)$

$\Rightarrow \lim\limits_{x\to 0^+} f(x) = \lim\limits_{x\to 0^+}\dfrac{x}{e^x-1} = \lim\limits_{x\to 0^+}\dfrac{1}{\frac{e^x-1}{x}} = 1$ (1pt)

(ព្រោះ: $\lim\limits_{x\to 0^+}\dfrac{e^x-1}{x} = 1$) (1pt)

ដូចនេះ: $\boxed{\lim\limits_{x\to 0^+} f(x) = 1}$ (1pt)

ចំពោះ $\lim\limits_{x\to +\infty} f(x) = \lim\limits_{x\to +\infty}\dfrac{x}{e^x-1} = \lim\limits_{x\to +\infty}\dfrac{x}{e^x}\left(\dfrac{1}{1-e^{-x}}\right)$

$= 0$ (1pt)

ព្រោះ: $\lim\limits_{u\to +\infty}\dfrac{u}{e^u} = 0, \ \lim\limits_{u\to +\infty} e^{-u} = 0$

ដូចនេះ:

$\boxed{\lim\limits_{x\to +\infty} f(x) = 0}$ (1pt)

③

២. ស្រាយបញ្ជាក់ថា $1+e^{\frac{1}{n}}+e^{\frac{2}{n}}+\dots+e^{\frac{n-1}{n}}=\frac{1-e}{1-e^{\frac{1}{n}}}$

គេមាន $1+e^{\frac{1}{n}}+e^{\frac{2}{n}}+\dots+e^{\frac{n-1}{n}}$

$=1+e^{\frac{1}{n}}+(e^{\frac{1}{n}})^2+\dots+(e^{\frac{1}{n}})^{n-1}$ (1pt)

$=1\cdot\frac{1-(e^{\frac{1}{n}})^n}{1-e^{\frac{1}{n}}}$ (1pt)

$=\frac{1-e}{1-e^{\frac{1}{n}}}$

ដូចនេះ $\boxed{1+e^{\frac{1}{n}}+e^{\frac{2}{n}}+\dots+e^{\frac{n-1}{n}}=\frac{1-e}{1-e^{\frac{1}{n}}}}$ (1pt)

បង្ហាញថា $U_n=(e-1)f(\frac{1}{n})$

គេមាន $U_n=\frac{1}{n}\left[1+e^{\frac{1}{n}}+e^{\frac{2}{n}}+\dots+e^{\frac{n-1}{n}}\right]$

$=\frac{1}{n}\cdot\frac{1-e}{1-e^{\frac{1}{n}}}=(e-1)\frac{\frac{1}{n}}{e^{\frac{1}{n}}-1}$ (1pt)

$=(e-1)f(\frac{1}{n})$

ដូចនេះ

$\boxed{U_n=(e-1)f(\frac{1}{n})}$ (1pt)

៣. រក $\lim\limits_{n\to+\infty}U_n$

$U_n=(e-1)f(\frac{1}{n})$

$\lim\limits_{n\to+\infty}U_n=\lim\limits_{n\to+\infty}(e-1)f(\frac{1}{n})$

$=\lim\limits_{x\to0}(e-1)f(x)$, តាង $x=\frac{1}{n}$ (2pt)

$=(e-1)$ ព្រោះ $\lim\limits_{x\to0}f(x)=1$ (2pt)

ដូចនេះ

$\boxed{\lim\limits_{n\to+\infty}U_n=e-1}$ (1pt)

V. (២០ពិន្ទុ) ស្រាយបញ្ជាក់ថា $BE=BF$

យើងមាន:

$\angle AEB=\angle PAE$ (មុំឆ្លាស់ក្នុង) (1pt)

$\angle PAE=\angle ABC$ (មុំចារឹកស្ទាត់ធ្នូរួម) (1pt)

$\Rightarrow\angle ABC=\angle AEB$ (1pt)



(5pt)

ក្នុង ΔABC និង ΔAEB គេមាន $\angle BAC$: មុំរួម (1pt)

$\angle ABC=\angle AEB$

នាំឲ្យ $\frac{BC}{BE}=\frac{AC}{AB}\Rightarrow BE=\frac{AB\times BC}{AC}$ (1pt) (1)

ΔABF និង ΔADB ដូចគ្នា

ព្រោះ: $\angle BAF$ រួម (1pt)

$\angle ADB=\angle PAB$ (មុំស្ទាត់ធ្នូរួម AB) (1pt)

$\angle PAB=\angle ABF$ (មុំឆ្លាស់ក្នុង) (1pt)

$\Rightarrow\angle ADB=\angle ABF$ (1pt)

នាំឲ្យ: $\Delta ABF\sim\Delta ADB\Rightarrow\frac{BF}{DB}=\frac{AB}{AD}$

$\Rightarrow BF=\frac{AB\times BD}{AD}$ (2) (1pt)

$\Delta PBC\sim\Delta PDB\Rightarrow\frac{BC}{BD}=\frac{PC}{PB}$ (2pt)

$\Delta PCA\sim\Delta PAD$ ដូចគ្នា $\Rightarrow\frac{AC}{AD}=\frac{PC}{PA}$ (2pt)

ដោយ $PA=PB$ (2pt)

$\Rightarrow\frac{BC}{BD}=\frac{AC}{AD}$ (3) (2pt)

តាម (1), (2), (3) គេបាន:

តាម (1) , (2) នឹង (3) គេបាន

$$BE = AB \times \frac{BC}{AC}$$

$$BF = AB \times \frac{BD}{AD}$$

$$\Rightarrow BE = BF \quad (2pt)$$

ដូចនេះ $\boxed{BE = BF}$

បាត់ដំបង ថ្ងៃទី 27 ខែ មេសា ឆ្នាំ 2017

អ្នកតាក់តែង

ទុំ. សំបត្តិ

បានឃើញ និង ឯកភាព

ប្រធានក្រុមគណិត

[illegible]

ឯកភាព

[illegible]

ប្រឡងជ្រើសរើសសិស្សពូកែទូទាំងប្រទេស

ផ្នែកអក្សរសិល្ប៍ខ្មែរ គណិតវិទ្យា និងរូបវិទ្យា ថ្នាក់ទី៩ និង ថ្នាក់ទី១២

សម័យប្រឡង ៖ ថ្ងៃទី២៣ ខែ មេសា ឆ្នាំ២០១៨

វិញ្ញាសាទី **១ ៖ គណិតវិទ្យា ថ្នាក់ទី១២** សម្រាប់ថ្ងៃទី២៣ ខែ មេសា ឆ្នាំ២០១៨

រយៈពេល ៖ ១៨០ នាទី ពិន្ទុ ៖ ១០០

ប្រធាន ៖

I. (២០ពិន្ទុ) គេមានត្រីកោណ ABC ។ ចំណុច D, E និង F ជាចំណុចកណ្តាលរៀងគ្នានៃជ្រុង BC, CA និង AB ។ ហើយ X, Y និង Z ជាជើង នៃកំពស់រៀងគ្នា គូសចេញពីកំពូល A, B និង C របស់ត្រីកោណ ABC ។ H ជាអរតូសង់នៃត្រីកោណ ABC ហើយ P, Q និង R ជាចំណុច កណ្តាលរៀងគ្នានៃអង្កត់ HA, HB, HC ។ បង្ហាញថាចំណុចទាំងប្រាំបួន $D, E, F, P, Q, R, X, Y, Z$ នៅលើរង្វង់តែមួយ ។

II. (១៥ពិន្ទុ) គេសន្មត $x, y \in (-2;2)$ និង $xy=-1$ ។កំណត់តម្លៃអប្បបរមារបស់ $u=\dfrac{4}{4-x^2}+\dfrac{9}{9-y^2}$ ។ ចូរជ្រើសរើសចម្លើយមួយដែលត្រូវ ។ $a.\dfrac{24}{11}$ $b.\dfrac{8}{5}$ $c.\dfrac{12}{7}$ $d.\dfrac{12}{5}$

កំណត់សម្គាល់: គ្រប់ចម្លើយដែលជ្រើសរើសត្រូវមានការស្រាយបំភ្លឺ ។ ចម្លើយដែលគ្មានការស្រាយបំភ្លឺ និងត្រូវបានពិន្ទុសូន្យ ។

III. (១០ពិន្ទុ) គេកំណត់ឱ្យរកមុំ θ ដែល $0<\theta<\dfrac{\pi}{2}$ ដើម្បីឱ្យសមីការដឺក្រេទី2 $x^2+4xCos\theta+Cot\theta=0$ (x ជាអញ្ញាត) មានឫសឌុប ។ រង្វាស់ θ គិតជារ៉ាដ្យង់ ។

IV. (១៥ពិន្ទុ) គេមាន x និង y ជាចំនួនពិតវិជ្ជមានមិនសូន្យដែលផ្ទៀងផ្ទាត់ $x^3+y^3=x-y$ ។ បង្ហាញថា $x^2+4y^2<1$ ។

V. (១០ពិន្ទុ) 1. កំណត់គ្រប់ចំនួនគត់ធម្មជាតិ n ដែល $\dfrac{n+27}{n+4}$ ជាចំនួនគត់ធម្មជាតិ ។

2. បង្ហាញថា: គ្រប់ចំនួនគត់ធម្មជាតិ n ប្រភាគ $\dfrac{2n+1}{3n+1}$ មិនអាចសម្រួលបាន ។

VI. (២០ពិន្ទុ) គេមានស្វ៊ីត (v_n) កំណត់ដោយ $v_1=\ln(2)$ និងចំពោះគ្រប់ចំនួនគត់ធម្មជាតិមិនសូន្យ n $v_{n+1}=\ln\left(2-e^{-v_n}\right)$ ។ គេសន្មតថាស្វ៊ីត (v_n) កំណត់ចំពោះគ្រប់ចំនួនគត់ធម្មជាតិ n មិនសូន្យ ។ គេកំណត់ស្វ៊ីត (S_n) ដែលចំពោះគ្រប់ចំនួនគត់ធម្មជាតិ n មិនសូន្យ គេបាន $S_n=\sum_{k=1}^{n}v_k=v_1+v_2+v_3+\ldots+v_n$ ។

គណនាលីមីត $\lim_{n\to+\infty} S_n$ ។

VII. (១០ពិន្ទុ) រកគ្រប់ចំនួនគត់វិជ្ជមានដាច់ខាត n ដែលគេបាន $A=n^4-4n^3+22n^2-36n+18$ ជាការេ នៃមួយចំនួនគត់វិជ្ជមានដាច់ខាត y ។

15

ប្រលងជ្រើសរើសសិស្សពូកែទូទាំងប្រទេស

ថ្នាក់គណិតវិទ្យា ថ្នាក់ទី12 វិញ្ញាសាទី1 ពិន្ទុ100

ថ្ងៃប្រឡងថ្ងៃទី 23 ខែ មេសា ឆ្នាំ 2018

រយៈពេល 180 នាទី

(20ពិន្ទុ) បង្ហាញថាចំណុចទាំង 9 D, E, F, P, Q, R, X, Y, Z នៅលើរង្វង់តែមួយ



(3ពិន្ទុ)

មាន $\left.\begin{array}{l} P \text{ កណ្តាល } AH \\ F \text{ កណ្តាល } AB \end{array}\right\} \Rightarrow PF \parallel BY$ (1ពិន្ទុ)

$\left.\begin{array}{l} F \text{ កណ្តាល } AB \\ D \text{ កណ្តាល } BC \end{array}\right\} \Rightarrow FD \parallel AC$ (1ពិន្ទុ)

ដោយ $BY \perp AC \Rightarrow BY \perp FD$ (1ពិន្ទុ)

$PF \parallel BY \Rightarrow PF \perp DF$ ត្រង់ F (1ពិន្ទុ)

នាំឲ្យ $\angle PFD = 90^\circ$ (1ពិន្ទុ)

ដោយស្រាយតាមរបៀបដូចគ្នា:

$\angle PED = \angle PRD = \angle PQD = 90^\circ$ (3ពិន្ទុ)

គេបាន 6 ចំណុច D, R, E, P, F, Q នៅលើរង្វង់ អង្កត់ផ្ចិត DP តែមួយ ① (1ពិន្ទុ)

ម្យ៉ាងទៀត $\angle PXD = 90^\circ$ នាំឲ្យ X នៅលើរង្វង់ អង្កត់ផ្ចិត DP ② (1ពិន្ទុ)

មាន ΔPHY សមបាត ($PY = \frac{AH}{2}$ មេដ្យានត្រី.កែង) (1ពិន្ទុ)

ΔBDY សមបាត ($YD = \frac{BC}{2}$ មេដ្យានត្រី.កែង) (1ពិន្ទុ)

នាំឲ្យ $\angle PYH = \angle PHY$

$\angle PHY = \angle BHX$ (ទល់កំពូល)

នាំឲ្យ $\angle PYH = \angle BHX$

និង $\angle DBY = \angle DYB$

ដោយ $\angle DBY + \angle BHX = 90^\circ$ (1ពិន្ទុ)

នាំឲ្យ $\angle PYH + \angle DYB = 90^\circ$ (1ពិន្ទុ)

Y ស្ថិតនៅលើរង្វង់អង្កត់ផ្ចិត DP ③ (1ពិន្ទុ)

ស្រាយតាមរបៀបដូចគ្នា Z នៅលើរង្វង់អង្កត់ផ្ចិត DP ④ (1ពិន្ទុ)

សរុបមក តាម ①, ②, ③ និង ④ 9 ចំណុច D, E, F, P, Q, R, X, Y, Z នៅលើរង្វង់ អង្កត់ផ្ចិត DP តែមួយ (1ពិន្ទុ)

II (15ពិន្ទុ) គណនាតម្លៃអប្បបរមានៃ U

យើងមាន $U = \frac{4}{4-x^2} + \frac{9}{9-y^2}$

$= \frac{4}{4-x^2} + \frac{9}{9-\frac{1}{x^2}}$ (ព្រោះ: $xy=-1, x\neq 0, y\neq 0$) (2ពិន្ទុ)

$= \frac{4}{4-x^2} + \frac{9x^2}{9x^2-1}$

$= \frac{4(9x^2-1)+9x^2(4-x^2)}{(4-x^2)(9x^2-1)}$

$= \frac{(-9x^4+37x^2-4)+35x^2}{-9x^4+37x^2-4}$ (2ពិន្ទុ)

$= 1 + \frac{35x^2}{-9x^4+37x^2-4}$

$= 1 + \frac{35}{-9x^2+37-\frac{4}{x^2}}$ (2ពិន្ទុ)

$= 1 + \frac{35}{37-(9x^2-2\cdot 3x\cdot\frac{2}{x}+\frac{4}{x^2}+12)}$

$U = 1 + \frac{35}{37-\left[(3x-\frac{2}{x})^2+12\right]}$ (2ពិន្ទុ)

U មានតម្លៃអប្បបរមាលុះត្រាតែ

$37-\left[(3x-\frac{2}{x})^2+12\right]$ យកតម្លៃធំបំផុត (2ពិន្ទុ)

ត្រូវនឹង $3x-\frac{2}{x}=0 \Leftrightarrow 3x^2-2=0$

$x^2 = \frac{2}{3}$

ដូច្នេះ $x=\pm\sqrt{\frac{2}{3}}$ (2 ពិន្ទុ)

ពេលនោះ $x=\pm\sqrt{\frac{2}{3}}$ គេបាន $U = 1+\frac{35}{37-(0+12)}$

$$= 1+\frac{35}{25}$$

$$U = \frac{12}{5}$$

ដូចនេះ ចម្លើយដែលត្រូវគឺ d. $\frac{12}{5}$ (3 ពិន្ទុ)

III (10 ពិន្ទុ) កំណត់រកមុំ θ

គេមាន $x^2+4x\cos\theta+\cot\theta=0$ មានឫសឌុប

គេបាន $\Delta' = (2\cos\theta)^2-\cot\theta=0$ (2 ពិន្ទុ)

$$\cot\theta\,(4\sin\theta\cos\theta-1)=0$$

$$\cot\theta\,(2\sin2\theta-1)=0 \quad (2 \text{ ពិន្ទុ})$$

ដោយ $0<\theta<\frac{\pi}{2} \Rightarrow \cot\theta\neq 0$ (2 ពិន្ទុ)

$\Rightarrow 2\sin2\theta-1=0$

$$\sin2\theta=\frac{1}{2}$$

$$\sin2\theta=\sin\frac{\pi}{6} \quad (2 \text{ ពិន្ទុ})$$

ដូចនេះ $\begin{cases}\theta=\frac{\pi}{12} & (1 \text{ ពិន្ទុ})\\ \theta=\frac{5\pi}{12} & (1 \text{ ពិន្ទុ})\end{cases}$

IV (15 ពិន្ទុ) បង្ហាញថា $x^2+4y^2<1$

ដោយមាន $x,y>0$ នោះ $x^3+y^3>0$

ហើយ $x-y>0$ (3 ពិន្ទុ)

$x^2+4y^2<1$ សមមូល:

$(x^2+4y^2)(x-y)<x^3+y^3$ (3 ពិន្ទុ)

$x^3+4xy^2-x^2y-4y^3<x^3+y^3$

$4xy^2 < x^2y+5y^3$

$4xy < x^2+5y^2$ ① (3 ពិន្ទុ)

តាមវិសមភាពកូស៊ី:

$x^2+5y^2 \geq 2\sqrt{x^2 5y^2} = 2\sqrt{5}\,xy > 4xy$

$x^2+5y^2 > 4xy$ ② (3 ពិន្ទុ)

① និង ② យើងបាន $x^2+4y^2<1$ ពិត

ដូចនេះ $x^2+4y^2<1$ (3 ពិន្ទុ)

V (10 ពិន្ទុ) 1) កំណត់ $n\in\mathbb{N}$ ដែល $\frac{n+27}{n+4}\in\mathbb{N}$

គេមាន $\frac{n+4+23}{n+4}\in\mathbb{N}$ (1 ពិន្ទុ)

$1+\frac{23}{n+4}\in\mathbb{N}$ (1 ពិន្ទុ)

គេបាន $(n+4)\,|\,23$ (1 ពិន្ទុ)

$\Rightarrow n+4=23$ (1 ពិន្ទុ)

$\Rightarrow n=19$ (1 ពិន្ទុ)

2) បង្ហាញថា $\forall n\in\mathbb{N}$ ប្រភាគ $\frac{2n+1}{3n+1}$ មិនអាចសម្រួលបាន

តាង $\gcd(2n+1,3n+1)=d$ (1 ពិន្ទុ)

គេបាន $\begin{cases}d\,|\,2n+1\\ d\,|\,3n+1\end{cases}$ ⇔ $\begin{cases}d\,|\,6n+3\\ d\,|\,6n+2\end{cases}$ (1 ពិន្ទុ)

$\Rightarrow d\,|\,(6n+3)-(6n+2)$ (1 ពិន្ទុ)

$\Rightarrow d\,|\,1$

$\Rightarrow d=1$ (1 ពិន្ទុ)

ដូចនេះ ប្រភាគ $\frac{2n+1}{3n+1}$ សម្រួលមិនបាន (1 ពិន្ទុ)

VI (20 ពិន្ទុ) គណនាលីមីត $\lim_{n\to+\infty} S_n$

$V_1=\ln2$, $V_{n+1}=\ln(2-e^{-V_n})$

តាង $U_{n+1}=e^{V_{n+1}}$ យើងបាន (2 ពិន្ទុ)

$U_{n+1}=e^{\ln(2-e^{-V_n})}=2-e^{-V_n}$ (2 ពិន្ទុ)

$$=2-\frac{1}{e^{V_n}}=2-\frac{1}{U_n}$$

$U_{n+1} = 2 - \frac{1}{U_n}$ (2 ពិន្ទុ)

ចំពោះ $n = 1, 2, 3$ គេបាន

$U_1 = e^{V_1} = e^{\ln 2} = 2 = \frac{1+1}{1}$ (2 ពិន្ទុ)

$U_2 = 2 - \frac{1}{U_1} = 2 - \frac{1}{2} = \frac{2+1}{2}$

$U_3 = 2 - \frac{1}{U_2} = 2 - \frac{1}{\frac{3}{2}} = \frac{3+1}{3}$

ឧបមាថាវាពិតដល់ $n = k$ គឺពិត $U_k = \frac{k+1}{k}$ (2 ពិន្ទុ)

ស្រាយថាវាពិតដល់ $n = k+1$

$U_{k+1} = 2 - \frac{1}{U_k} = 2 - \frac{1}{\frac{k+1}{k}}$

$= 2 - \frac{k}{k+1}$

$= \frac{2(k+1)-k}{k+1}$

$U_{k+1} = \frac{(k+1)+1}{k+1}$ ពិត (4 ពិន្ទុ)

ដូចនេះ $U_{n+1} = \frac{n+2}{n+1}$

$\Rightarrow e^{V_{n+1}} = \frac{n+2}{n+1}$

$V_{n+1} = \ln\left(\frac{n+2}{n+1}\right)$

$V_{n+1} = \ln(n+2) - \ln(n+1)$ (2 ពិន្ទុ)

គេបាន

$$\begin{cases} V_1 = \ln 2 - \ln 1 \\ V_2 = \ln 3 - \ln 2 \\ - - - - - - \\ V_n = \ln(n+1) - \ln n \end{cases}$$

$S_n = \ln(n+1) - \ln 1$ (2 ពិន្ទុ)

$= \ln(n+1)$ ព្រោះ $\ln 1 = 0$

$\Rightarrow \lim_{n\to+\infty} S_n = \lim_{n\to+\infty} \ln(n+1) = +\infty$

ដូចនេះ $\lim_{n\to+\infty} S_n = +\infty$ (2 ពិន្ទុ) 3

VII (10 ពិន្ទុ) រកចំនួនគត់រ៉ឺឡាទីប n ដែល $A = n^4 - 4n^3 + 22n^2 - 36n + 18$ ជាការេនៃចំនួនគត់រ៉ឺឡាទីបមួយ

$A = n^4 - 4n^3 + 22n^2 - 36n + 18$

$= n^4 - 4n^3 + 4n^2 + 18n^2 - 36n + 18$ (1 ពិន្ទុ)

$A = n^2(n-2)^2 + 18n(n-2) + 18$

តាង $A = y^2$, $x = n(n-2)$, $(x+1) = (n-1)^2 \geq 0$ (1 ពិន្ទុ)

$\Rightarrow y^2 = x^2 + 18x + 18$

$\Rightarrow y^2 = (x+9)^2 - 63$

$\Rightarrow (x+9)^2 - y^2 = 63$

$\Rightarrow (x+9-y)(x+9+y) = 63$ (1 ពិន្ទុ)

ដោយ $63 = 1 \times 63 = 3 \times 21 = 7 \times 9$

ដែល $x+9-y < x+9+y$

គេបាន $(x+9-y, x+9+y) = (1, 63), (3, 21), (7, 9), (-63, -1), (-21, -3), (-9, -7)$ (1 ពិន្ទុ)

ករណី $(x+9-y, x+9+y) = (1, 63), (3, 21), (7, 9)$

$(x, y) = (23, 31), (3, 9), (-1, 2)$ (1 ពិន្ទុ)

ករណី $(x+9-y, x+9+y) = (-63, -1), (-21, -3), (-9, -7)$

$(x, y) = (-41, 31), (-21, 9), (-17, 1)$ (1 ពិន្ទុ)

ដោយ $x + 1 \geq 0 \Rightarrow x \geq -1$

ដូច្នេះ ករណីទី២ មិនយក៖

④

- បើ $x=23 \Rightarrow n^2-2n=23$

$$(n-1)^2=24$$

គ្មាន n គត់ (1 ពិន្ទុ)

- បើ $x=3$ នាំឲ្យ $n^2-2n=3$

$$(n-1)^2=4$$

$$n-1=2$$

$$n=3$$ (1 ពិន្ទុ)

បើ $x=-1 \Rightarrow n^2-2n=-1$

$$(n-1)^2=0$$

$$n=1$$ (1 ពិន្ទុ)

ចម្លើយ $n=1$, $n=3$ (1 ពិន្ទុ)

ថ្ងៃទី 23 ខែ តុលា ឆ្នាំ 2018

អ្នកតាក់តែង

ស្វាង ភក្តីដារា

បានឃើញ និងឯកភាព

ប្រធាន ក្រុមកិច្ចការ

ជី សារ៉ាវលី

ឯកភាព

ប្រធានគណៈកម្មការ

ពិល ភារិន

ប្រឡងជ្រើសរើសសិស្សពូកែទូទាំងប្រទេស

ផ្នែកអក្សរសិល្ប៍ខ្មែរ គណិតវិទ្យា និងរូបវិទ្យា ថ្នាក់ទី៩ និង ថ្នាក់ទី១២

....

សម័យប្រឡង ៖ ថ្ងៃទី២៣ ខែ មេសា ឆ្នាំ២០១៨

វិញ្ញាសាទី **២ ៖ គណិតវិទ្យា ថ្នាក់ទី១២** សម្រាប់ថ្ងៃទី**២៥ ខែ មេសា ឆ្នាំ២០១៨**

រយៈពេល ៖ ១៨០ នាទី ពិន្ទុ ៖ ១០០

ប្រធាន ៖

I. (១០ពិន្ទុ) ដោះស្រាយក្នុងសំណុំចំនួនពិត $\mathbb{R}$ វិសមីការ $\sqrt{\log_2 x-1}+\frac{1}{2}\log_{\frac{1}{2}} x^3+2>0$ ។

II. (២០ពិន្ទុ) គេមានត្រីកោណ ABC និង O ជាចំណុចនៅក្នុងត្រីកោណ ABC ដែលបំពេញលក្ខខណ្ឌ $\overline{OA}+2\overline{OB}+3\overline{OC}=\bar{0}$ ។ រកផលធៀបរវាងផ្ទៃក្រឡារបស់ត្រីកោណ ABC និងផ្ទៃក្រឡារបស់ត្រីកោណ AOC ។

III. (១០ពិន្ទុ) គេមានអនុគមន៍ $f:\mathbb{R}\to\mathbb{R}$ កំណត់ដោយ $f(0)=1$ និង ចំពោះគ្រប់ $x,y\in\mathbb{R}$, $f(xy+1)=f(x)f(y)-f(y)-x+2$ យកលំនាំបែបនេះ ។ ចូរកំណត់ $f(x)$?

IV. (១៥ពិន្ទុ) គណនាផលបូក :

$$S_n=\ln\left(1+\frac{1}{Cosx}\right)+\ln\left(1+\frac{1}{Cos2x}\right)+\ln\left(1+\frac{1}{Cos2^2x}\right)+.....+\ln\left(1+\frac{1}{Cos2^{n-1}x}\right)$$ ។

V. (១០ពិន្ទុ) បង្ហាញថា $(2^{33}-1)$ ចែកដាច់នឹង 7 ។

VI. (១០ពិន្ទុ) ស្រាយបំភ្លឺដោយប្រើវិចារអនុមានរួមគណិតវិទ្យាថា ចំពោះគ្រប់ចំនួនគត់ធម្មជាតិ n មិនសូន្យ គេបាន: $n!\geq 2^{n-1}$ ។

VII. (១៥ពិន្ទុ) គេមានបន្ទាត់ (d) ដែលមានសមីការ $y=\frac{5}{4}x-\frac{2}{3}$ ។

1. បង្ហាញថាបើ (x,y) ជាគូនៃចំនួនគត់រ៉ឺឡាទីប នោះចំនួនគត់ $15x-12y$ ចែកដាច់នឹង 3 ។
2. តើមានចំណុចនៃបន្ទាត់ (d) ដែលកូអរដោនេជាពីរចំនួនគត់រ៉ឺឡាទីបឬទេ ? ចូរស្រាយបំភ្លឺ ។

VIII. (១០ពិន្ទុ) បង្ហាញថាគ្រប់ចំនួនគត់ធម្មជាតិ n លេខខ្ទង់រាយនៃចំនួន $p=n^2+n$ មិនអាចស្មើរនឹង4 ជាដាច់ខាត ។

15

សម្រាំកំណែលសញ្ញាបត្រ គណិតវិទ្យាទុតិយភូមិ

